កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មការទន្លេមេគង្គ (MRC/FMMP)

ផ្នែកទី ៤: គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)

# សៀវភៅណែនាំ

# ស្តីពី

# របៀបរៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

# សំរាប់ថ្នាក់រាជធានី-ខេត្ត និង ក្រុង-ស្រុក-ខណ្ឌ

**មិថុនា ២០១០**

**Table of contents**


**Part I: guidance book**

- Is what guidance book?
- Objectives of guidance book
- Guidance book is prepared for whom?

**Part II: Guideline on disaster risk reduction plan pattern**

## 1. Introduction
1.1 What is disaster risk reduction plan?
1.2 Planning development process
1.3 Who is responsible for planning development
1.4 Planning necessity

## 2. Principles guideline for development of disaster risk reduction plan
2.1 General principles guideline
2.2 Preface
2.3 Plan characteristics

## 3. Principles guideline of each part
3.1 Provincial or district profile
A. Geography
B. Land size
C. Population
D. Economy
E. Education
F. Health
G. Safe area
H. Transportation
I. Irrigation system
3.2 Disaster Background
A. Disaster background
B. Hazard and risk analysis
C. Capacity analysis
D. Briefing of disaster risk

## 4. Disaster risk reduction plan
4.1 Strategies
A. Vision of disaster risk reduction
B. Strategic goal
4.2 Plan and strategic actions
A. Preparedness response (Before disaster)
B. Response and emergency recue (During disaster)
C. Recovery and restroation (After disaster)

**Part III: Plan implementation and monitoring**

1. Roles and responsibilities of provincial and district committee for disaster management.
2. Roles and responsibilities of line departments/agencies and offices in province and district.

**Annexes**

- Structure of provincial/district and commune disaster management
- Four intervention teams and their roles and responsibilities
- Pattern of Flood preparedness plan
- Other documents

# មាតិកា


## ផ្នែកទី ១: អំពីសៀវភៅណែនាំ

- អ្វីជាសៀវភៅណែនាំ?
- គោលបំណងនៃសៀវភៅណែនាំ
- សៀវភៅណែនាំនេះចងក្រងឡើងសំរាប់អ្នកណា?

## ផ្នែកទី ២: សេចក្តីណែនាំលើទំរង់គំរូនៃផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

១. សេចក្តីផ្តើម

១.១ អ្វីជាផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ?

១.២ ដំណើរការនៃការរៀបចំផែនការ

១.៣ អ្នកណាជាអ្នករៀបចំផែនការ?

១.៤ សារ:សំខាន់នៃផែនការ

២. គោលការណ៍ណែនាំសំរាប់រៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

២.១ គោលការណ៍ណែនាំទូទៅ

២.២ អារម្ភកថា

២.៣ លក្ខណៈនៃផែនការ

៣. គោលការណ៍ណែនាំតាមផ្នែកនីមួយៗ

៣.១ ប្រវត្តិរបស់ខេត្ត ឬ ស្រុក

ក- ទីតាំងភូមិសាស្រ្ត

ខ- ទំហំផ្ទៃដី

គ- ប្រជាជន

ឃ- សេដ្ឋកិច្ច

ង- ការអប់រំ

ច- សុខាភិបាល

ឆ- ទីទួលសុវត្ថិភាព

ជ- មធ្យោបាយដឹកជញ្ជូន

ញ- ប្រពន្ធ័ធារាសាស្រ្ត

៣.២ ប្រវត្តិគ្រោះមហន្តរាយ

ក- ប្រវត្តិគ្រោះមហន្តរាយ

ខ- ការវិភាគមុខសញ្ញាគ្រោះថ្នាក់ និង គ្រោះភ័យ

គ- ការវិភាគសមត្ថភាព

ឃ- សេចក្តីសង្ខេបពីគ្រោះភ័យនៃគ្រោះមហន្តរាយ

### ៤. ផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

#### ៤.១ យុទ្ធសាស្ត្រ

ក- ចក្ខុវិស័យនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ខ- គោលដៅយុទ្ធសាស្ត្រ

#### ៤.២ ផែនការ និង សកម្មភាពយុទ្ធសាស្ត្រ

ក- ដំណាក់កាលត្រៀមបង្ការសំរាប់ឆ្លើយតប (មុនពេលគ្រោះមហន្តរាយ)

ខ- ដំណាក់កាលឆ្លើយតប និងសង្គ្រោះបន្ទាន់ (ក្នុងពេលគ្រោះមហន្តរាយ)

គ- ដំណាក់កាលស្តារ និងជួសជុលឡើងវិញ (ក្រោយពេលគ្រោះមហន្តរាយ)

## ផ្នែកទី ៣: ការអនុវត្តន៍ផែនការ និងការតាមដានត្រួតពិនិត្យ

១- ភារកិច្ច និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី- ខេត្ត និង ក្រុង-ស្រុក-ខណ្ឌ

២- ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ទីរ/អង្គភាព និងការិយាល័យជុំវិញរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ

## ឧបសម្ពន្ធ៍ផ្សេងៗ

- របទាសម្ពន្ធ័គ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ និង ឃុំ-សង្កាត់
- ក្រុមអន្តរាគមន៍ទាំង០៤ និង ភារកិច្ច/ការទទួលខុសត្រូវរបស់ក្រុមនីមួយៗ
- ទំរង់គំរូនៃផែនការត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់
- ឯកសារផ្សេងៗទៀត

# ផ្នែកទី ១:
# អំពីសៀវភៅណែនាំ

## ១.១ អ្វីជាសៀវភៅណែនាំ?

សៀវភៅណែនាំនេះ ចងក្រងឡើងសំរាប់ជាឧបករណ៍ជំនួយផ្នែកស្មារតី និងបច្ចេកទេស ដល់អ្នកមានភារកិច្ច-តួនាទីលើការងាររៀបចំ និង អនុវត្តផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទាំងឡាយនៅក្នុងប្រទេសកម្ពុជា។ សៀវភៅណែនាំខាងលើនេះ ចែកចេញជា០៣ផ្នែកសំខាន់ៗ:

- ផ្នែកទី ១: អំពីសៀវភៅណែនាំ
- ផ្នែកទី ២: សេចក្តីណែនាំលើទំរង់គំរូនៃផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ
- ផ្នែកទី ៣: ការអនុវត្តន៏ផែនការ និងការត្រួតពិនិត្យតាមដាន

## ១.២ គោលបំណងនៃសៀវភៅណែនាំ

- ដើម្បីប្រើប្រាស់ជាឯកសារជំនួយ សំរាប់ធ្វើការណែនាំពីរបៀបរៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅកំរិតថ្នាក់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ។ ផែនការអាចមាន: ផែការត្រៀមបង្ការគ្រោះទឹកជំនន់, រាំងស្ងួត, ខ្យល់ព្យុះ សត្វល្អិតបំផ្លាញដំណាំ និង ជំងឺរាតត្បាត ផ្សេងៗ ជាដើម ។ល។
- ដើម្បីកំណត់ជាបទដ្ឋានមួយច្បាស់លាស់ពីទំរង់គំរូរបស់ផែនការដែលមានលក្ខណ:ផ្សេងៗគ្នាទៅតាមប្រភេទនៃគ្រោះមហន្តរាយដូចបានរៀបរាប់ខាងលើ។
- សំរាប់ជាជំនួយដល់គណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ និង ស្ថាប័ន/អង្គការនានា ដែលអនុវត្តការងារគ្រប់គ្រងនិងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា សំរាប់រៀបចំផែនការរបស់ខ្លួន។
- ដើម្បីធ្វើការប៉ាន់ប្រមាណពីធនធាន និង សមត្ថភាព ដែលមានស្រាប់នៅថ្នាក់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ក៏ដូចជា ការកៀងគរជំនួយគាំទ្រពីដៃគូខាងក្រៅ ដើម្បីអនុវត្តផែនការរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ១.៣ សៀវភៅណែនាំនេះចងក្រងឡើងសំរាប់អ្នកណា?

សៀវភៅណែនាំចងក្រងនេះត្រូវបានចងក្រងឡើងសំរាប់ប្រើប្រាស់ជាឧបករណ៍ជំនួយដល់:

- លេខាធិការដ្ឋានគណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយកំរិតថ្នាក់រាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ។
- មន្ទីរវិស័យ អង្គភាព និងការិយាល័យទាំងអស់ ដែលជាសមាជិកគណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ។
- អង្គការ ស្ថាប័នជាតិ-អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងអនុវត្តសកម្មភាពគ្រប់គ្រងនិងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា។

# ផ្នែកទី ២:

# សេចក្តីណែនាំលើទំរង់គំរូនៃផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

## ១. សេចក្តីផ្តើម

### ១.១ អ្វីជាផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ?

គឺជាផែនការដែលបានរៀបចំឡើងដោយអាជ្ញាធរ ផ្នែកនានា អង្គការ ឬ សហគ្រាស ដែលបានកំណត់ពីទិសដៅ, គោលបំណង និងសកម្មភាពជាក់លាក់នានា សំរាប់កាត់បន្ថយឱ្យបានជាអតិបរមានូវគ្រោះភ័យនៃគ្រោះមហន្តរាយផ្សេងៗ។ ក្នុងនោះដែរ ប្រភព និងការបែងចែកធនធានតម្រូវការ(រូបបវត្ថុ និងអរូបវត្ថុ) ពេលវេលា និងការទទួលខុសត្រូវ គួរត្រូវបានកំណត់នៅក្នុងផែនការនេះ។

### ១.២ ដំណើរការនៃការរៀបចំផែនការ

ខាងក្រោមនេះ គឺជាការបរិយាយពិស្តារអំពីដំណើរការរៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដែលចែកចេញជា ០៤ដំណាក់កាលសំខាន់ៗ:

**-ដំណាក់កាលទី ១ (ការកសាងសមត្ថភាព)**:វាមានសារៈសំខាន់ណាស់ក្នុងការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលផ្សេងៗដល់អ្នករៀបចំនិងអនុវត្តផែនការទាំងឡាយ ដើម្បីពួកគេមានចំណេះដឹងទូលំទូលាយ និង សមត្ថភាពគ្រប់គ្រាន់ មុននឹងចាប់ផ្តើមរៀបចំផែនការ។ ដំណើរការវគ្គ គួររៀបចំឡើងឱ្យមានរយៈពេលសមស្របទៅតាមចំនួនសិក្ខាកាម និងខ្លឹមសាររបស់មេរៀន។ ចំពោះខ្លឹមសារមេរៀនផ្សេងៗ ដែលគួរលើកយកមកធ្វើការបណ្តុះបណ្តាល គឺត្រូវតែទាក់ទងយ៉ាងពិតប្រាកដជាមួយនឹងទស្សនាទាននៃការគ្រប់គ្រងនិងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា ដូចមាននៅក្នុងសៀវភៅបណ្តុះបណ្តាល ស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដែលបានរៀបចំនិងផ្សព្វផ្សាយដោយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)។

**-ដំណាក់កាលទី ២ (ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព)**: សិក្ខាកាមទាំងអស់ ដែលបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដំណាក់កាលទី១ខាងលើ នឹងត្រូវបានលើកទឹកចិត្តសំរាប់ចូលរួមនៅក្នុងវគ្គដំណាក់កាលទី២ ដើម្បីបានសិក្សាផ្នែកទ្រឹស្តីនិងចុះអនុវត្តផ្ទាល់នៅទីវាល ពីរបៀបប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព ជាមួយអាជ្ញាធរដែនដី និង សហគមន៍។

**-ដំណាក់កាលទី ៣ (ការរៀបចំពង្រាងផែនការសកម្មភាព)**: ផ្អែកលើទិន្នន័យនិងពិតមានទាក់ទិននឹងមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព ដែលអ្នករៀបចំនិងអនុវត្តទាំងឡាយបានចុះសិក្សា និងរកឃើញពីបញ្ហានិងតម្រូវការផ្សេងៗរបស់សហគមន៍ដែលងាយរងគ្រោះក្នុងដំណាក់កាលទី២ខាងលើ គឺពិតជាមានសារៈសំខាន់ណាស់ សំរាប់រៀបចំអ្នករៀបចំនិងអនុវត្ត (មានៈ លេខាធិការដ្ឋាន, មន្ទីរអង្គភាពជុំវិញរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ) ដើម្បីរៀបចំនូវពង្រាងផែនការសកម្មភាពឱ្យស្របនឹងកម្មវិធីស្នូលតាមបណ្តាមន្ទីរអង្គភាពនីមួយៗរបស់ពួកគេ។ នៅក្នុងដំណាក់កាលនេះ លេខាធិការដ្ឋាន ឬក្រុមការងារ អាចដើរតួនាទីសំខាន់លើការងារចុះផ្តល់ការណែនាំបច្ចេកទេសបន្ថែមដល់គ្រប់មន្ទីរ អង្គភាព និងការិយាល័យ ដើម្បីឱ្យ

ការរៀបចំសរសេរពង្រាងផែនការសកម្មភាពកាន់តែមានលក្ខណៈច្បាស់លាស់ ពេញលេញ និង ស៊ីជំរៅ។ សូមបញ្ជាក់ថា ចំពោះរយៈពេលនៃការសរសេរពង្រាងផែនការនេះ គួរទុកពេលវេលាយ៉ាងតិច ០១សប្តាហ៍។

**-ដំណាក់កាលទី ៤ (ការពិនិត្យ កែសំរួល អនុម័ត និងផ្សព្វផ្សាយ):** សិក្ខាសាលាមួយ ត្រូវបានរៀបចំឡើង ដើម្បីធ្វើការពិនិត្យ និង កែសំរួល លើគ្រប់ពង្រាងផែនការសកម្មភាពរបស់មន្ទីរ-អង្គភាព និង ការិយាល័យ នីមួយៗ។ នៅចុងបញ្ចប់នៃសិក្ខាសាលា ផែនការសកម្មភាពដែលបានធ្វើការកែសំរួលរួចហើយនោះ ត្រូវបាន អនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់/អនុវត្តជាផ្លូវការ។

ខាងក្រោមនេះ គឺជាវដ្តនៃដំណើរការរៀបចំ កែសំរួល និងអនុវត្ត លើផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ:




## ១.៣ អ្នកណាជាអ្នករៀបចំ, កែសំរួល និង អនុវត្តផែនការ?

មន្ទីរ-អង្គភាព និងការិយាល័យទាំងអស់ជុំវិញខេត្ត និងស្រុក គឺជាអ្នករៀបចំ, កែសំរួល, ធ្វើបច្ចុប្បន្នភាព និង អនុវត្តលើផែនការ។

## ១.៤ សារៈសំខាន់នៃផែនការ

### *ក- ហេតុអ្វីចាំបាច់មានផែនការ?*

ផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ វាជាវិធានការ ឬសកម្មភាព សម្រាប់អនុវត្តជាមុន ដើម្បីធ្វើឱ្យការឆ្លើយតប និង ស្តារឡើងវិញ ពីផលប៉ះពាល់ដោយគ្រោះទឹកជំនន់បានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ផែនការនេះមានទិសដៅនិងតួនាទី ០២យ៉ាង ដូចខាងក្រោម:

- វាយតម្លៃធនធាន និងសមត្ថភាពដែលមានស្រាប់នៅគ្រប់ថ្នាក់ រួមមាន: ថ្នាក់ស្រុក ឃុំ និង ភូមិ។

- រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការងារត្រៀមបង្ការ ប្រតិបត្តិការឆ្លើយតបសង្គ្រោះ និងស្តារឡើងវិញទាំងនៅក្នុងដំណាក់កាលមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ឧទាហរណ៍ ដូចជា: ការផ្តល់ព័ត៌មាន ជាមុនពីគ្រោះថ្នាក់ដែលអាចកើតឡើងឱ្យទាន់ពេលវេលា ការជម្លៀសប្រជាជន និងទ្រព្យសម្បត្តិជាមុនពី កន្លែងគ្រោះថ្នាក់ រៀបចំជំរកបណ្តោះអាសន្ន ការស្តុកទុកជំនួយសង្គ្រោះ និងការរៀបចំប្រព័ន្ធទំនាក់ទំនង ជាដើម ។

*ខ- តើផែនការអាចជួយយើងបានអ្វីខ្លះ?*

ផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ អាចជួយឱ្យមានការរៀបចំ និងកំណត់ពីធនធាន សម្រាប់ប្រើប្រាស់ក្នុងការកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ ។ ការរៀបចំផែនការបានល្អអាចជួយយើងនៅក្នុងការងារមួយចំនួនធំ ដូចខាងក្រោម:

- អាចធ្វើឱ្យសហគមន៍ងាយរងគ្រោះអាចទទួលបានព័ត៌មានបានទាន់ពេលវេលាដូចជា ព័ត៌មានព្យាករណ៍ និង ព័ត៌មានប្រកាសភាពអាសន្ន ជាដើម ។
- អាចផ្តល់ឱ្យនូវសេចក្តីត្រូវការចាំបាច់ ដូចជា ជំរកបណ្តោះអាសន្ន ការថែទាំសុខភាព ទឹកស្អាត និង ម្ហូបអាហារដល់ជនរងគ្រោះ ។
- អាចកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជន ។
- អាចធ្វើការស្តារឡើងវិញបានទាន់ពេលវេលា នូវផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ។
- ធ្វើឱ្យមានកិច្ចសហការល្អ និងមានប្រសិទ្ធភាពក្នុងចំណោមអង្គការនិងស្ថាប័ន្ធពាក់ព័ន្ធ ក្នុងការឆ្លើយតប នៅពេលកើតមានគ្រោះគ្រោះមហន្តរាយ ។
- ធ្វើឱ្យសហគមន៍វិលត្រឡប់ទៅរកស្ថានភាពដើមវិញបានយ៉ាងឆាប់រហ័ស ក្រោយពីគ្រោះមហន្តរាយ ។

## ២. គោលការណ៍ណែនាំសំរាប់រៀបចំផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ២.១ គោលការណ៍ណែនាំទូទៅ

### ២.២ អារម្ភកថា

អារម្ភកថា គឺជាខ្លឹមសាររួមនៃវត្ថុបំណងរបស់សៀវភៅ ដែលអ្នករៀបចំចង់បង្ហាញដល់អ្នកអាននិងអ្នកប្រើប្រាស់ ។ ក្នុងការតាក់តែងឡើង អ្នករៀបចំពុំគួរសរសេរមានលក្ខណៈវែងពេកទេ យ៉ាងច្រើនត្រឹមមួយទំព័រ ។ អារម្ភកថា ត្រូវបង្ហាញ អំពីសារៈប្រយោជន៍របស់ផែនការ ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមចំណែកកសាងផែនការ និងការរំពឹងទុកដែលសង្ឃឹមថានឹងទទួលបានការចូលរួមគាំទ្រពីអ្នកពាក់ព័ន្ធទាំងឡាយ ។ នៅចុងបញ្ចប់នៃអារម្ភកថានេះ អភិបាលរាជធានី - ខេត្ត និងក្រុង-ស្រុក-ខណ្ឌ ត្រូវចុះហត្ថលេខា ព្រមទាំងដាក់ឈ្មោះ មុខងាររបស់ខ្លួន និង កាលបរិច្ឆេទ ។ អារម្ភកថា គួររក្សាទុកមួយទំព័រ ដាច់ដោយឡែក ។

២.៣ លក្ខណៈនៃផែនការ

# ៣. គោលការណ៍ណែនាំតាមផ្នែកនីមួយៗ

## ៣.១ ប្រវត្តិរបស់រាជធានី-ខេត្ត ឬ ក្រុង-ស្រុក-ខណ្ឌ

### ក- ទីតាំងភូមិសាស្ត្រ

- ត្រូវសរសេររៀបរាប់ពីទីតាំងរបស់រាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌទាំងនោះវាស្ថិតនៅទិសខាងណានៃផ្ទៃប្រទេស, រាជធានីភ្នំពេញ ឬទីរួមខេត្ត ដែលមានព្រំប្រទល់ខាងកើត, ខាងលិច, ខាងត្បូង និងខាងជើង ជាប់នឹង......មានចម្ងាយប៉ុន្មានគីឡូម៉ែត្រពីចំណុចប្រៀបធៀបខាងលើ និងមានផ្លូវជាតិណា ឬ ទន្លេ-ស្ទឹងសំខាន់ៗណាខ្លះ ដែលហូរឆ្លងកាត់ ជាដើម ។ល ។
- បន្ទាប់មក ត្រូវសរសេរពីពត៌មានទាក់ទិននឹងចំនួនក្រុង/ស្រុក/ខណ្ឌ, ឃុំ និងភូមិ ទាំងអស់ដែលមាននៅក្នុងបញ្ជីរដ្ឋបាលផ្លូវការ ដូចមានតារាងគំរូបង្ហាញខាងក្រោមៈ

| ល.រ | ឈ្មោះក្រុង ឬ ស្រុក-ខណ្ឌ | ចំនួនឃុំ/សង្កាត់ | ចំនួនភូមិ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| --- | | | |
| សរុបៈ | | | |

### ខ- ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋៈ

| ល.រ | ឈ្មោះស្រុក/ក្រុង ឬ ឃុំ | ចំនួនគ្រួសារ | ចំនួនមនុស្ស | ប្រុស | ស្រី |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| --- | | | | | |
| សរុបៈ | | | | | |

### គ- ទំហំផ្ទៃដី

ចំនួនផ្ទៃដី និង ប្រភេទដីៈ ត្រូវសរសេររៀបរាប់ពីចំនួនផ្ទៃដីសរុបទូទាំងរាជធានី-ខេត្ត ឬស្រុក-ក្រុងមានប៉ុន្មាន

ហ.ត។ ក្នុងនោះផ្ទៃដីចែកចេញជាប៉ុន្មានហិកតា សំរាប់ធ្វើកសិកម្ម, ស្រូវប្រាំង, ស្រូវវស្សា, ផ្ទៃដីចំការ, ដីព្រៃ, ផ្ទៃដីព្រែក បឹងបួរ-ទន្លេ, ដីសំណង់សាធារណៈ, ដីលំនៅដ្ឋាន ជាដើម។ បន្ទាប់មកត្រូវបំពេញពិតមានដោយលើកយកតែផ្ទៃដីសំរាប់បង្កបង្កើនផលមួយមុខប៉ុណ្ណោះមកលំអិតជាតួលេខនៅតាមបណ្ដា ក្រុង-ស្រុក-ខណ្ឌ ឬ ឃុំ-សង្កាត់ នីមួយៗ ដូចមានក្នុងតារាងគំរូបង្ហាញខាងក្រោមៈ

| ល.រ | ឈ្មោះក្រុង/ស្រុក ឬ ឃុំ | ដីស្រែ | | | |
|---|---|---|---|---|---|
| | | ស្រែវស្សា | | ស្រែប្រាំង | |
| | | ពឹងទឹកភ្លៀង (ហ.ត) | បញ្ចូលទឹកបង្ហូរ (ហ.ត) | បញ្ចូលទឹកទាំងស្រុង (ហ.ត) | ស្រូវស្រាល (ហ.ត) |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| --- | | | | | |
| **សរុប** | | | | | |

## ឃ- សេដ្ឋកិច្ច

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋៈ អ្នករៀបចំផែនការ ត្រូវសរសេររៀបរាប់អំពីមុខរបរសំខាន់ៗជាងគេដែលប្រជាពលរដ្ឋភាគច្រើនក្នុងរាជធានី-ខេត្ត ឬក្រុង-ស្រុក-ខណ្ឌ បានប្រកបរបរចិញ្ចឹមជីវិត។ តមកទៀត ត្រូវសរសេររៀបរាប់ពីមុខរបរនិងការងារបន្ទាប់បន្សំដទៃទៀតផងដែរ ជាមួយនឹងហេតុផលផ្សេងៗដែលបណ្ដាលឱ្យប្រជាពលរដ្ឋទៅប្រកបមុខរបរបន្ទាប់បន្សំខាងលើ។ ជាចុងក្រោយ ពិតមានស្ដីពី ប្រភេទមុខរបរនីមួយៗ(គិតជា%) គួរត្រូវបានបំពេញបន្ថែមនៅក្នុងតារាងគំរូបង្ហាញខាងក្រោមៈ

| ប្រភេទមុខរបរ | ភាគរយ (%) |
|---|---|
| កសិកម្ម | --- % |
| លក់ដូរ | --- % |
| ចិញ្ចឹមសត្វ | --- % |
| ឡើងត្នោត | --- % |
| ដាំដំណាំ | --- % |
| គ្រួសារធ្វើចំណាកស្រុក (ប្រចាំថ្ងៃ) | --- % |
| គ្រួសារធ្វើចំណាកស្រុក យូរអង្វែង (រយៈពេល៦ខែឡើង) | --- % |

## ង- ការអប់រំ

| ល.រ | ប្រភេទសិស្ស | សរុប (នាក់) | សិស្សស្រី | សិស្សប្រុស |
|---|---|---|---|---|
| ១ | មហាវិទ្យាល័យ | | | |
| ២ | វិទ្យាល័យ | | | |
| ៣ | អនុវិទ្យាល័យ | | | |
| ៤ | បឋមសិក្សា | | | |
| ៥ | មត្តេយ្យសិក្សា | | | |

## ច- សុខាភិបាល

| ល.រ | ស្រុក/ក្រុង ឃុំ/សង្កាត់ | មណ្ឌលសុខភាព | *បុគ្គលិក* | ស្រុកប្រតិបត្តិ | *បុគ្គលិក* | មន្ទីរពេទ្យបង្អែក | *បុគ្គលិក* |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| -- | | | | | | | |
| **សរុប** | | | | | | | |

## ឆ- ទីទួលសុវត្ថិភាព (សាលារៀន វត្តអារាម និង ទួលសុវត្ថិភាព)

| ស្រុក/ក្រុង ឬ ឃុំ/សង្កាត់ | មត្តេយ្យសិក្សា | | | បឋមសិក្សា | | | មធ្យមសិក្សា | | | វត្តអារាម | ទីទួលសុវត្ថិភាព |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនខ្នង | គ្រូប្រុស | គ្រូស្រី | ចំនួនខ្នង | គ្រូប្រុស | គ្រូស្រី | ចំនួនខ្នង | គ្រូប្រុស | គ្រូស្រី | | |
| ១ --- | | | | | | | | | | | |
| ២ --- | | | | | | | | | | | |
| ៣ --- | | | | | | | | | | | |
| ---- | | | | | | | | | | | |
| **សរុប** | | | | | | | | | | | |

## ជ- មធ្យោបាយដឹកជញ្ជូន

| លរ | ស្រុក/ក្រុង ឃុំ/សង្កាត់ | ម៉ូតូ | ត្រាក់ទ័រ | គោយន្ត ភ្ជួរស្រែ | គោយន្ត កែឆ្នៃ | រទេះ គោ/សេះ | កង់ | ទូកអុំ /ចែវ | ទូកម៉ាស៊ីន /កាណូត |
|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ៣ | | | | | | | | | |
| -- | | | | | | | | | |
| **សរុប** | | | | | | | | | |

ឈ- ប្រពន្ធ័ធារាសាស្ត្រ

| ល.រ | ស្រុក/ក្រុង<br>ឃុំ/សង្កាត់ | ព្រែក | ប្រឡាយ | ភ្លឺភ្លោះ | អូរ | អាង | ស្ទឹង | ទន្លេ | បឹង(ធំ) |
|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ៣ | | | | | | | | | |
| -- | | | | | | | | | |
| **សរុប** | | | | | | | | | |

ញ- ប្រពន្ធ័ទំនាក់ទំនង

អ្នករៀបចំ គួរដាក់ឈ្មោះ មុខងារ និងលេខទូរសព្ទ័ទំនាក់ទំនង របស់ប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតាមលំដាប់ឋានានុក្រម និង តាមប្រភេទកិរិតនៃសៀវភៅផែនការ ។ ឧទាហរណ៍: សំរាប់ផែនការកិរិតថ្នាក់រាជធានី (ចាប់ពីអភិបាលរាជធានី ដល់ អភិបាលខណ្ឌ), ផែនការកិរិតថ្នាក់ខេត្ត (ពីអភិបាលខេត្ត ដល់ អភិបាលក្រុង-ស្រុក-ខណ្ឌ) និង ផែនការកិរិតថ្នាក់ក្រុង-ស្រុក-ខណ្ឌ (ពីអភិបាលក្រុង-ស្រុក-ខណ្ឌ ដល់ មេភូមិ) ។ ខាងក្រោម គឺជាតារាងគំរូបង្ហាញ:

| ល.រ | ឈ្មោះ | តួនាទី/មុខងារ/អង្គភាព | ទូរសព្ទ័ទំនាក់ទំនង |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| -- | | | |

## ៣.២ ប្រវត្តិគ្រោះមហន្តរាយ

ក- ប្រវត្តិគ្រោះមហន្តរាយ

អ្នករៀបចំត្រូវសរសេររៀបរាប់ពីប្រវត្តិនៃគ្រោះមហន្តរាយចម្បងៗនានាដែលបានកើតឡើង និងបង្កផលប៉ះពាល់កន្លងមកនៅក្នុងរាជធានី-ខេត្ត ឬក្រុង-ស្រុក-ខណ្ឌរបស់ខ្លួន រួមមាន: ចំនួនមនុស្ស (ស្លាប់ របួស គ្មានទីជំរក) សត្វ ទ្រព្យសម្បត្តិ ផ្ទះសម្បែង ផលដំណាំ កសិកម្ម និង ចំនួនភូមិ-ឃុំ/សង្កាត់ ក្រុង-ស្រុក-ខណ្ឌ ហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗដែលបានទទួលរងការប៉ះពាល់និងខូចខាតដោយគ្រោះមហន្តរាយ និងកាលបរិច្ឆេទនីមួយៗ ឱ្យបានពិស្តារ ។ ខាងក្រោមនេះ គឺជាតារាងគំរូបន្ថែម សំរាប់ពិតមានទាក់ទិននឹងគ្រោះមហន្តរាយតាមបណ្តាឆ្នាំ និងឥទ្ធិពលរបស់វា :

***១. តារាងវិភាគពីប្រភេទគ្រោះមហន្តរាយតាមឆ្នាំ*** (តារាង ឧទាហរណ៍)

| ល.រ | ប្រភេទមុខសញ្ញា | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | --- | --- |
|---|---|---|---|---|---|---|---|---|---|
| ១ | ទឹកជំនន់ | x xx | | x x | | x | | | |
| ២ | រាំងស្ងួត | | | | x x | | x | | |
| ៣ | ខ្យល់ព្យុះ | x | | | | | x x | | |
| ៤ | ជំងឺមនុស្ស (រាតត្បាត) | | x x | | x | | | | |
| ៥ | វន្ទះបាញ់ | | | | | x | | x xx | |
| ៦ | គ្រោះថ្នាក់ចរាចរ | | | | | | | | x x |
| --- | .................. | | | | | | | | |

*កំណត់សំគាល់: x = តិចតួច/ស្រាល, xx = មធ្យម, xxx = ធំ ឬ ធ្ងន់ធ្ងរ*

### ២-តារាងតួលេខពីផលប៉ះពាល់ដោយគ្រោះមហន្តរាយតាមបណ្តាឆ្នាំ

| លរ | ប្រភេទនៃផលប៉ះពាល់ | ២០០០ | ២០០១ | ២០០២ | ២០០៣ | -- | -- | -- | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | ចំនួនមនុស្សស្លាប់ (នាក់) | | | | | | | | |
| ២ | ចំនួនគ្រួសារការប៉ះពាល់ | | | | | | | | |
| ៣ | ចំនួនប្រជាជនរងការប៉ះពាល់ | | | | | | | | |
| ៤ | ចំនួនឃុំរងការប៉ះពាល់ | | | | | | | | |
| ៥ | ចំនួនភូមិរងការប៉ះពាល់ | | | | | | | | |
| ៦ | ចំនួនផ្ទះរងការខូចខាត | | | | | | | | |
| ៧ | ចំនួនផ្ទះរងការខូចខាតដោយអគ្គិភ័យ | | | | | | | | |
| ៨ | ចំនួនផ្ទះរងការខូចខាតដោយខ្យល់ព្យុះ | | | | | | | | |
| ៩ | ចំនួនស្ពានរងការខូចខាត | | | | | | | | |
| ១០ | ប្រវែងផ្លូវលំរងការខូចខាត | | | | | | | | |
| ១១ | ស្រូវវស្សារងការខូចខាត(ហត) | | | | | | | | |
| ១២ | ស្រូវប្រាំងរងការខូចខាត(ហត) | | | | | | | | |
| ១៣ | ដំណាំអនុផលរងការខូចខាត(ហត) | | | | | | | | |
| ១៤ | ចំនួនសត្វពាហនៈងាប់ | | | | | | | | |
| ១៥ | ចំនួនសាលារៀនរងការខូចខាត | | | | | | | | |
| -- | ------- | | | | | | | | |

## ខ- ការវិភាគប្រភេទមុខសញ្ញាគ្រោះថ្នាក់

សូមប្រើប្រាស់តារាងខាងក្រោមនេះ(តារាង ១) សំរាប់ធ្វើការវិភាគពីប្រភេទមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ:

***<u>តារាង ១</u>: រៀបរាប់ពីមុខសញ្ញាគ្រោះថ្នាក់ គ្រោះមហន្តរាយដែលកើតឡើងកំឡុងពេល ១០ រឺ ២០ឆ្នាំ ចុងក្រោយ? និង រៀបរាប់ផងដែរនូវមុខសញ្ញាគ្រោះថ្នាក់ដែលអ្នកគិតថា វានឹងអាចកើតឡើងក្នុង ពេលអនាគត:***

| មុខសញ្ញា គ្រោះថ្នាក់ (១) | ភាព ញឹកញាប់ (២) | ច្រើនដង ក្នុង១ឆ្នាំ (៣) | រៀង រាល់ឆ្នាំ (៤) | ៥ឆ្នាំ ម្តង (៥) | ១០ឆ្នាំ ម្តង (៦) | ពេល កើត (៧) | ឥទ្ធិពល/ប៉ះពាល់ | | | សញ្ញា សំគាល់ (១១) | ការ ប្រែប្រួល (១២) | ទីតាំង មុខសញ្ញា (១៣) | អាទិ ភាព (១៤) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ទាប (៨) | ធម្យម (៩) | ខ្លាំង ១០ | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

***ចំណាំ :*** *សូមពន្យល់ពីភាពញឹកញាប់នៃមុខសញ្ញាគ្រោះថ្នាក់ ច្រើនដងក្នុងមួយឆ្នាំ កើតឡើងរាល់ឆ្នាំ ៥ឆ្នាំម្តង ឬ ១០ឆ្នាំម្តង, ឥទ្ធិពលរបស់វា, សញ្ញាសំគាល់, ការប្រែប្រួល, ទីតាំងមុខសញ្ញា និង ចំណាត់អាទិភាពរបស់វា ។ សូមផ្តល់ព័ត៌មានពីឆ្នាំដែលមុខសញ្ញាគ្រោះថ្នាក់បានកើតឡើង ។ បន្ទាប់ពីបំពេញព័ត៌មាននេះរួចហើយ សូមស្នើសុំការឯកភាពជារួមលើមុខសញ្ញាគ្រោះថ្នាក់ជាអាទិភាពយ៉ាងតិចចំនួន ៥ ។*

### ➢ ***<u>ការណែនាំពីរបៀបបំពេញព័តមានក្នុងតារាង ១:</u>***

- **កូឡោនលេខ ១:** អ្នកវិភាគត្រូវសរសេរពីប្រភេទមុខសញ្ញាគ្រោះថ្នាក់ចម្បងៗផ្សេងៗឱ្យបានយ៉ាងតិច ៥ ដែលតែងកើតឡើង និងបង្កផលប៉ះពាល់នៅក្នុងភូមិសាស្រ្តរបស់អ្នក (ឧទាហរណ៍: ទឹកជំនន់, រាំងស្ងួត, ខ្យល់ព្យុះ, ជំងឺរាតត្បាត និង រន្ទះបាញ់ ជាដើម) ។
- **កូឡោនលេខ ២,៣,៤,៥ និង ៦:** ធ្វើការវិភាគថាតើមុខសញ្ញាគ្រោះថ្នាក់នីមួយៗ តែងកើតឡើងច្រើនក្នុងមួយឆ្នាំ, រៀងរាល់ឆ្នាំ, ៥ឆ្នាំម្តង ឬ ក៏រវាង១០ឆ្នាំម្តង។ ចំពោះពិតមាននៅក្នុងកូឡោនទាំងអស់ដូចបានរៀបរាប់ ខាងលើ(ចាប់ពីលេខ ២ ដល់ ៦) អ្នកវិភាគគ្រាន់តែគូស☑ នៅក្នុងកូឡោនណាមួយដែលអ្នក/ក្រុមគិតថា ជាពិតមានត្រឹមត្រូវ គឺជាការស្រេច (បញ្ជាក់: មុខសញ្ញាគ្រោះថ្នាក់មួយ គឺអាចគូសបានតែមួយកូឡោនប៉ុណ្ណោះ) ។
- **កូឡោនលេខ ៧:** អ្នកវិភាគ ត្រូវកំណត់ពីឆ្នាំជាក់លាក់ណាមួយ ឬ ពីចន្លោះឆ្នាំណា ដល់ ឆ្នាំណាមួយ ដែលមុខសញ្ញាគ្រោះថ្នាក់ទាំងនោះបានកើតឡើង (ផ្អែកលើយោបល់ចូលរួមភាគច្រើន នៅក្នុងក្រុមពិភាក្សា ឬ អង្គសិក្ខាសាលា) ។
- **កូឡោនលេខ ៨,៩, ១០:** អ្នកវិភាគ ត្រូវគូស☑នៅក្នុងកូឡោនមួយ ក្នុងចំនោមកូឡោនទាំងបី ដើម្បីបញ្ជាក់ពីឥទ្ធិពលរបស់វា (ទាប ឬខ្សោយ, មធ្យម, ខ្លាំង ឬធ្ងន់ធ្ងរ) ។

- **កូឡោនលេខ ១១:** អ្នកវិភាគ ត្រូវគិតពីសញ្ញាសំគាល់ណាអ្វីជាតឹកតាងដែលសហគមន៍តែងបានកំណត់ចំណាំ ដើម្បីសំគាល់ពីឥទ្ធិពលរបស់មុខសញ្ញាគ្រោះថ្នាក់នីមួយៗនៅតាមមូលដ្ឋានរបស់ពួកគេ ទោះបីការចំណាំនោះមានលក្ខណៈបែបធម្មជាតិ ឬ វិទ្យាសាស្ត្រក្តី គួរត្រូវបានលើកយកមកបំពេញនៅក្នុងតារាង (ឧទាហរណ៍- ការកំណត់ចំណាំតាមបែបធម្មជាតិចំពោះគ្រោះទឹកជំនន់ ថាតើឆ្នាំនេះ ទឹកតូច ឬ ធំ: អ្នកស្រុកតែងសំគាល់ថា នៅរៀងរាល់រដូវចូលឆ្នាំ នាថ្ងៃវរៈឡើងសក្ត (ថ្ងៃទី៣) ប្រសិនបើទឹកទន្លេជន់ឡើងខ្ពស់ (ទឹកនាច) នោះឆ្នាំនេះ នឹងមានទឹកឡើងធំ ឬទឹកជំនន់ធំជាពុំខាន។ ការសំគាល់ចំណាំខ្លះ ទៀតគេសំគាល់ទៅលើសកម្មភាពរបស់សត្វស្រមោច ដែលបានពាំចំណីអាហារទៅលាក់ទុកនៅទីកន្លែងខ្ពស់ៗ ជាដើម។ រីឯការសំគាល់បែបវិទ្យាសាស្ត្រ គឺផ្អែកទាំងស្រុងទៅលើសារពិតមាននៃការព្យាករណ៍តាមវិទ្យុ ទូរទស្សន៍ និង ការជូនដំណឹងពីសំណាក់អាជ្ញាធរដែនដី។
- **កូឡោនលេខ ១២:** សំរាប់សំគាល់និងពិចារណាទៅលើឥទ្ធិពលនៃប្រភេទមុខសញ្ញាគ្រោះថ្នាក់នីមួយៗ ដែលបានកើតឡើង ថាតើ វានៅមានសភាពដដែល, តិច/ខ្សោយ ឬ ក៏រឹតតែខ្លាំងក្លា/ធ្ងន់ធ្ងរជាងពេល/បណ្តាឆ្នាំមុនៗ (ធ្វើការប្រៀបធៀបពីឥទ្ធិពលរបស់វារវាងអតីតកាល និង ពេលបច្ចុប្បន្ន)។
- **កូឡោនលេខ ១៣:** អ្នកវិភាគ ត្រូវបញ្ជាក់ពីចំណុចទីតាំងភូមិសាស្ត្រទាក់ទិនជាមួយមុខសញ្ញាគ្រោះថ្នាក់នីមួយៗដែលបានកើតឡើងកន្លងមកនោះ វាស្ថិតនៅប៉ែកណា, តំបន់ណា ឬ ទិសខាងណានៃស្រុក, ឃុំ, ភូមិ (ប្រសិនបើរៀបរាប់បានជាក់លាក់ពីឈ្មោះរបស់ឃុំ និង ភូមិ ដែលតែងប្រឈម រឹតតែប្រសើរ)។
- **កូឡោនលេខ ១៤:** អ្នកសំរបសំរួល គួរបំផុសឱ្យអ្នកចូលរួមទាំងអស់នៅក្នុងក្រុមពិភាក្សា ឬ អង្គសិក្ខា-សាលាទាំងមូល ធ្វើការសំដែងមតិចូលរួមថាតើ ក្នុងចំនោមមុខសញ្ញាគ្រោះថ្នាក់ទាំងអស់ខាងលើ មួយណាមានអាទិភាពខ្ពស់ បង្គួរ មធ្យម ឬ ទាប ផ្អែកតាមរយៈសំលេងបោះឆ្នោត។ ក្នុងសកម្មភាពបោះឆ្នោតនេះ អ្នកសំរបសំរួល ត្រូវផ្តល់ឱកាសដល់អ្នកចូលរួម/សិក្ខាកាមគ្រប់គ្នា ដែលមានវត្តមានក្នុង សិក្ខាសាលា ឬ ក្រុមពិភាក្សា បានឡើងដាក់ពិន្ទុតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗដែលមាននៅក្នុង កូឡោនលេខ ១។ អ្នកចូលរួម ត្រូវបានផ្តល់សិទ្ធិក្នុងការសំរេចចិត្តដោយខ្លួនឯងដើម្បីឡើងទៅដាក់ពិន្ទុម្នាក់ម្តងៗទៅលើមុខសញ្ញាគ្រោះថ្នាក់ទាំង៥ ដែលខ្លួនពេញចិត្ត (សូមបញ្ជាក់ថា: អ្នកចូលរួមម្នាក់ៗ មានសិទ្ធិដាក់ពិន្ទុ បានចំនួនប្រាំពិន្ទុ គឺពីចាប់ ១ពិន្ទុ ដល់ ៥ពិន្ទុ (***ពីពិន្ទុ ១-២= អាទិភាពទាប/តិចតួច, ៣=មធ្យម/ប៉ះពាល់ និង ៤-៥= ខ្ពស់/ធ្ងន់ធ្ងរ/ប៉ះពាល់ខ្លាំង***) ហើយក្នុងមួយកូឡោនៗ គឺអាចបង់បានតែមួយលេខប៉ុណ្ណោះ)។
- បន្ទាប់ពីអ្នកចូលរួមទាំងអស់បានឡើងដាក់ពិន្ទុគ្រប់គ្នាហើយ អ្នកសំរបសំរួលត្រូវធ្វើការបូកសរុបពិន្ទុតាមមុខសញ្ញាគ្រោះថ្នាក់នីមួយៗ។ ប្រសិនបើមុខសញ្ញាគ្រោះថ្នាក់ណាមានពិន្ទុច្រើនជាងគេ គឺអាទិភាពខ្ពស់/ធ្ងន់ធ្ងរ ឬប៉ះពាល់ខ្លាំង (**អាទិភាពទី១**)។ មុខសញ្ញាគ្រោះថ្នាក់ណាមានពិន្ទុច្រើនបន្ទាប់ (**អាទិភាពទី២**), មុខសញ្ញាណាមានពិន្ទុបន្ទាប់ (**អាទិភាពទី៣**), មុខសញ្ញាណាមានពិន្ទុបន្ទាប់មកទៀត (**អាទិភាពទី៤**) និង មុខសញ្ញាណាមានពិន្ទុតិចជាងគេ គឺទាប/ខ្សោយ/ពុំសូវធ្ងន់ធ្ងរ (**អាទិភាពទី ៥**)។

## ខ- ការវិភាគភាពងាយរងគ្រោះ និង គ្រោះភ័យ

ការវិភាគ

ខាងក្រោមនេះ គឺជាតារាងគំរូសំរាប់ប្រើប្រាស់ក្នុងការវិភាគពីភាពងាយរងគ្រោះ និងគ្រោះភ័យ:

***តារាង ២: ផ្នែកងាយរងគ្រោះ និង គ្រោះភ័យ សំរាប់មុខសញ្ញាគ្រោះថ្នាក់ទីមួយៗ:***

ក្នុងមួយតារាង គឺសំរាប់ធ្វើការវិភាគលើមុខសញ្ញាគ្រោះថ្នាក់ស្ថិតក្នុងអាទិភាពមួយប៉ុណ្ណោះ។ អ្នកវិភាគ ត្រូវបំពេញពិតមាន លំអិតនៅក្នុងតារាងខាងក្រោមនេះម្តងមួយៗ ដោយផ្តោតលើមុខសញ្ញាគ្រោះថ្នាក់ដែលស្ថិតក្នុងអាទិភាពទាំង ៥ ខាងលើ):

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ១**

| មុខសញ្ញាគ្រោះថ្នាក់ (អាទិភាពទី ១) (១) | ភាពងាយរងគ្រោះ ហេតុអ្វី? (២) | | គ្រោះភ័យ (៣) |
|---|---|---|---|
| | **១. មនុស្ស:** | | |
| | *-ចាស់ជរា* | | |
| | *-ស្ត្រីមានផ្ទៃពោះ* | | |
| | *-កុមារ* | | |
| | *-ជនពិការ* | | |
| | *-ស្ត្រីមេម៉ាយ* | | |
| | **២. កសិកម្ម:** | | |
| | *-ស្រូវ* | | |
| | *-ដំណាំផ្សេងៗ* | | |
| | *-ការចិញ្ចឹមត្រី* | | |
| | **៣. សុខភាព:** | | |
| | *-អាគារ* | | |
| | *-ជម្ងឺរាតត្បាត* | | |
| | *-ពេទ្យ* | | |
| | **៤- អប់រំ:** | | |
| | *-សាលារៀន* | | |
| | *-សិស្ស* | | |
| | *-គ្រូបង្រៀន* | | |
| | *-សម្ភារៈ និង អគារសិក្សា* | | |
| | **៥. សត្វពាហន:** | | |

| | | | |
|---|---|---|---|
| | -គោក្របី | | |
| | -ជំងឺសត្វ | | |
| | -........ | | |
| | **៦. ហេដ្ឋារចនាសម្ព័ន្ធ:** | | |
| | -ផ្លូវថ្នល់ | | |
| | -មន្ទីរពេទ្យ | | |
| | -ប្រពន្ធ័ធារាសាស្ត្រ | | |
| | **៧. បរិស្ថានធម្មជាតិ:** | | |
| | - បរិស្ថានធម្មជាតិ | | |
| | - .... | | |
| | **៨. មុខរបរ និង ការងារ:** | | |
| | -មុខរបរ និង ការងារ | | |
| | - --- | | |

**មុខសញ្ញគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ២**

| មុខសញ្ញាគ្រោះថ្នាក់ (អាទិភាពទី ២) (១) | ភាពងាយរងគ្រោះ | | គ្រោះភ័យ (៣) |
|---|---|---|---|
| | ហេតុអ្វី? (២) | | |
| | **១. មនុស្ស:** | | |
| | -ចាស់ជរា | | |
| | -ស្ត្រីមានផ្ទៃពោះ | | |
| | -កុមារ | | |
| | -ជនពិការ | | |
| | -ស្ត្រីមេម៉ាយ | | |
| | **២. កសិកម្ម:** | | |
| | -ស្រូវ | | |
| | -ដំណាំផ្សេងៗ | | |
| | -ការចិញ្ចឹមត្រី | | |
| | **៣. សុខភាព:** | | |
| | -អាគារ | | |
| | -ជម្ងឺរាតត្បាត | | |
| | -ពេទ្យ | | |
| | **៤- អប់រំ:** | | |

| | | | |
|---|---|---|---|
| | *-សាលារៀន* | | |
| | *-សិស្ស* | | |
| | *-គ្រូបង្រៀន* | | |
| | *-សម្ភារៈ និង អគារសិក្សា* | | |
| | **<u>៥. សត្វពាហនៈ</u>** | | |
| | *-គោក្របី* | | |
| | *-ជម្ងឺសត្វ* | | |
| | -........ | | |
| | **<u>៦. ហេដ្ឋារចនាសម្ព័ន្ធ:</u>** | | |
| | *-ផ្លូវថ្នល់* | | |
| | *-មន្ទីរពេទ្យ* | | |
| | *-ប្រពន្ធ័ធារាសាស្រ្ត* | | |
| | **<u>៧. បរិស្ថានធម្មជាតិ:</u>** | | |
| | *- បរិស្ថានធម្មជាតិ* | | |
| | - ....... | | |
| | <u>៨. មុខរបរ និង ការងារ:</u> | | |
| | *-មុខរបរ និង ការងារ* | | |
| | - --- | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ៣**

| មុខសញ្ញាគ្រោះថ្នាក់ (អាទិភាពទី ៣) (១) | ភាពងាយរងគ្រោះ | | គ្រោះភ័យ |
|---|---|---|---|
| | ហេតុអ្វី? (២) | | (៣) |
| | **<u>១. មនុស្ស:</u>** | | |
| | *-ចាស់ជរា* | | |
| | *-ស្ត្រីមានផ្ទៃពោះ* | | |
| | *-កុមារ* | | |
| | *-ជនពិការ* | | |
| | *-ស្ត្រីមេម៉ាយ* | | |
| | **<u>២. កសិកម្ម:</u>** | | |
| | *-ស្រូវ* | | |
| | *-ដំណាំផ្សេងៗ* | | |

| | | | |
|---|---|---|---|
| | -ការចិញ្ចឹមត្រី | | |
| | **៣. សុខភាពៈ** | | |
| | *-អាគារ* | | |
| | *-ជម្ងឺរាតត្បាត* | | |
| | *-ពេទ្យ* | | |
| | **៤- អប់រំៈ** | | |
| | *-សាលារៀន* | | |
| | *-សិស្ស* | | |
| | *-គ្រូបង្រៀន* | | |
| | *-សម្ភារៈ និង អគារសិក្សា* | | |
| | **៥. សត្វពាហនៈ** | | |
| | *-គោក្របី* | | |
| | *-ជំងឺសត្វ* | | |
| | -........ | | |
| | **៦. ហេដ្ឋារចនាសម្ព័ន្ធៈ** | | |
| | *-ផ្លូវថ្នល់* | | |
| | *-មន្ទីពេទ្យ* | | |
| | *-ប្រពន្ធ័ធារាសាស្រ្ត* | | |
| | **៧. បរិស្ថានធម្មជាតិៈ** | | |
| | *- បរិស្ថានធម្មជាតិ* | | |
| | - .... | | |
| | **៨. មុខរបរ និង ការងារៈ** | | |
| | *-មុខរបរ និង ការងារ* | | |
| | - --- | | |

**មុខសញ្ញាគ្រោះថ្នាក់  ស្ថិតក្នុងអាទិភាពទី  ៤**

| មុខសញ្ញាគ្រោះថ្នាក់ (អាទិភាពទី ៤) (១) | ភាពងាយរងគ្រោះ | | គ្រោះភ័យ (៣) |
|---|---|---|---|
| | ហេតុអ្វី? (២) | | |
| | **១. មនុស្សៈ** | | |
| | *-ចាស់ជរា* | | |
| | *-ស្ត្រីមានផ្ទៃពោះ* | | |

| | | | |
|---|---|---|---|
| | -កុមារ | | |
| | -ជនពិការ | | |
| | -ស្ត្រីមេម៉ាយ | | |
| | **២. កសិកម្ម:** | | |
| | -ស្រូវ | | |
| | -ដំណាំផ្សេងៗ | | |
| | -ការចិញ្ចឹមត្រី | | |
| | **៣. សុខភាព:** | | |
| | -អាគារ | | |
| | -ជម្ងឺរាតត្បាត | | |
| | -ពេទ្យ | | |
| | **៤- អប់រំ:** | | |
| | -សាលារៀន | | |
| | -សិស្ស | | |
| | -គ្រូបង្រៀន | | |
| | -សម្ភារ: និង អគារសិក្សា | | |
| | **៥. សត្វពាហនៈ** | | |
| | -គោក្របី | | |
| | -ជំងឺសត្វ | | |
| | -........ | | |
| | **៦. ហេដ្ឋារចនាសម្ព័ន្ធ:** | | |
| | -ផ្លូវថ្នល់ | | |
| | -មន្ទីពេទ្យ | | |
| | -ប្រពន្ធ័ធារាសាស្ត្រ | | |
| | **៧. បរិស្ថានធម្មជាតិ:** | | |
| | - បរិស្ថានធម្មជាតិ | | |
| | - .... | | |
| | **៨. មុខរបរ និង ការងារ:** | | |
| | -មុខរបរ និង ការងារ | | |
| | - --- | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ៥**

| មុខសញ្ញាគ្រោះថ្នាក់ (អាទិភាពទី ៥) (១) | ភាពងាយរងគ្រោះ | ហេតុអ្វី? (២) | គ្រោះភ័យ (៣) |
|---|---|---|---|
| | **១. មនុស្ស:** | | |
| | *-ចាស់ជរា* | | |
| | *-ស្ត្រីមានផ្ទៃពោះ* | | |
| | *-កុមារ* | | |
| | *-ជនពិការ* | | |
| | *-ស្ត្រីមេម៉ាយ* | | |
| | **២. កសិកម្ម:** | | |
| | *-ស្រូវ* | | |
| | *-ដំណាំផ្សេងៗ* | | |
| | *-ការចិញ្ចឹមត្រី* | | |
| | **៣. សុខភាព:** | | |
| | *-អាគារ* | | |
| | *-ជម្ងឺរាតត្បាត* | | |
| | *-ពេទ្យ* | | |
| | **៤- អប់រំ:** | | |
| | *-សាលារៀន* | | |
| | *-សិស្ស* | | |
| | *-គ្រូបង្រៀន* | | |
| | *-សម្ភារៈ និង អគារសិក្សា* | | |
| | **៥. សត្វពាហនៈ** | | |
| | *-គោក្របី* | | |
| | *-ជំងឺសត្វ* | | |
| | -........ | | |
| | **៦. ហេដ្ឋារចនាសម្ព័ន្ធ:** | | |
| | *-ផ្លូវថ្នល់* | | |
| | *-មន្ទីរពេទ្យ* | | |
| | *-ប្រពន្ធ័ធារាសាស្ត្រ* | | |
| | **៧. បរិស្ថានធម្មជាតិ:** | | |

| | | | |
|---|---|---|---|
| | *- បរិស្ថានធម្មជាតិ* | | |
| | - .... | | |
| | **៨. មុខរបរ និង ការងារ:** | | |
| | *-មុខរបរ និង ការងារ* | | |
| | - --- | | |

### ➢ *ការណែនាំពីរបៀបបំពេញពិតមានក្នុងតារាង ២:*

- **កូឡោនលេខ ១:** អ្នកវិភាគ គ្រាន់តែត្រូវដាក់ឈ្មោះមុខសញ្ញាគ្រោះថ្នាក់ដែលស្ថិតនៅក្នុងអាទិភាពទី១, ២,៣, ៤ និង ៥ គឺជាការស្រេច។ ( *បញ្ជាក់: ត្រូវចងចាំថា ការដាក់ឈ្មោះមុខសញ្ញាគ្រោះថ្នាក់ទាំងនេះ គឺក្នុងមួយតារាង គឺដាក់បានតែមួយមុខសញ្ញាអាទិភាពប៉ុណ្ណោះ សំរាប់លើកយកមកធ្វើការវិភាគ*) ។
- **កូឡោនលេខ ២:** ត្រូវធ្វើការវិភាគឱ្យបានល្អិតល្អន់លើបណ្តាធាតុទាំងអស់នៃភាពងាយរងគ្រោះដែលមាននៅក្នុងតារាងតាមលំដាប់លំដោយនៃធាតុនីមួយៗពីលើមកក្រោម ដើម្បីរកឱ្យឃើញថាតើកត្តាអ្វីខ្លះដែលអាចធ្វើធាតុនៃភាពងាយរងគ្រោះទាំងនោះ ងាយនឹងទទួលរងការគំរាមកំហែងបំផុតពីមុខសញ្ញាគ្រោះថ្នាក់នីមួយៗនៅពេលគ្រោះមហន្តរាយកើតឡើង។ ការវិភាគនេះ ត្រូវផ្អែកលើកត្តា បីយ៉ាង: ១-ភាពងាយរងគ្រោះផ្នែករូបរាង ឬសំភារៈ, ២-ភាពងាយរងគ្រោះផ្នែកសង្គម, និង ៣-ភាពងាយរងគ្រោះផ្នែកអត្តចរិក។ ឧទាហរណ៍: ការវិភាគលើ( កត្តាមនុស្ស) ថាតើហេតុអ្វីបានជា *កុមារ* ងាយរងគ្រោះ? ហេតុផល គឺកុមារ មានសម្បទាទន់ខ្សោយ ឈឺថ្កាត់ច្រើន គ្មានទីពឹង/អនាថា ពុំបានចូលសាលារៀន ពុំទាន់មានបទពិសោធន៍រស់នៅក្នុងសង្គម ពុំទាន់ចេះហែលទឹក គ្មានអនាម័យ( រស់នៅ, ហូប-ផឹក) ខ្វះជីវជាតិអាហារូបត្ថម្ភ អត្រាស្លាប់ច្រើន នៅក្នុងតំបន់នោះពុំទាន់មានមណ្ឌលគាំពារកុមារ ជាដើម ។ល។
- **កូឡោនលេខ ៣:** អ្នកវិភាគ ត្រូវធ្វើការសន្និដ្ឋានខ្លីមួយនៅគ្រប់ធាតុនីមួយៗនៃភាពងាយរងគ្រោះដែលបានវិភាគនៅគ្រប់តារាងពីលើមកក្រោម។ ឧទាហរណ៍: ប្រសិនបើអ្នកវិភាគលើមុខសញ្ញាគ្រោះថ្នាក់ស្តីពីគ្រោះទឹកជំនន់ គឺបញ្ហាគ្រោះភ័យដែលត្រូវធ្វើការសន្និដ្ឋានសំរាប់កុមារ គឺ*អាចលង់ទឹកស្លាប់*។

## គ- ការវិភាគពីសមត្ថភាព

ការវិភាគ។។។។។។។។។។។។។។។។។។។។។។។

ខាងក្រោមនេះ គឺជាតារាងគំរូសំរាប់ប្រើប្រាស់ក្នុងការវិភាគពីធនធាន និងសមត្ថភាព ផ្អែកលើមុខសញ្ញាគ្រោះថ្នាក់នីមួយៗស្ថិតក្នុងអាទិភាពទាំង ០៥ខាងលើ:

***តារាង ៣: ការវិភាគធនធាន និងសមត្ថភាព សំរាប់មុខសញ្ញាគ្រោះថ្នាក់ស្ថិតក្នុងអាទិភាពនីមួយៗ:***

ក្នុងមួយតារាង គឺសំរាប់ធ្វើការវិភាគលើមុខសញ្ញាគ្រោះថ្នាក់ស្ថិតក្នុងអាទិភាពមួយប៉ុណ្ណោះ។ អ្នកវិភាគ ត្រូវបំពេញពិតមានលំអិតនៅក្នុងតារាងខាងក្រោមនេះម្តងមួយៗ ដោយផ្តោតលើមុខសញ្ញាគ្រោះថ្នាក់ដែលស្ថិតក្នុងអាទិភាពទាំង ៥ ខាងលើ):

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ១:** ..................................................................

| ប្រភេទនៃធនធាន<br>(១) | តើធនធានអ្វីដែលមាន ស្រាប់ក្នុងសហគមន៍<br>(២) | គាំទ្រដោយ រដ្ឋាភិបាល<br>(៣) | គាំទ្រដោយ អង្គការ, និង ផ្នែកឯកជន<br>(៤) | គាំទ្រដោយ សហគមន៍<br>(៥) | ភាពខ្វះចន្លោះ និង តម្រូវការធនធានបន្ថែម<br>(៦) |
|---|---|---|---|---|---|
| **ស្ថាប័ន** (គណៈកម្មាការ, អង្គការ, សមាគម,ក្រុមមនុស្ស.. | | | | | |
| **សំភារៈ និង ថវិកា** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| **ចំណេះដឹង/ជំនាញផ្សេងៗ** | | | | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ២:** ..................................................................

| ប្រភេទនៃធនធាន<br>(១) | តើធនធានអ្វីដែលមាន ស្រាប់ក្នុងសហគមន៍<br>(២) | គាំទ្រដោយ រដ្ឋាភិបាល<br>(៣) | គាំទ្រដោយ អង្គការ, និង ផ្នែកឯកជន<br>(៤) | គាំទ្រដោយ សហគមន៍<br>(៥) | ភាពខ្វះចន្លោះ និង តម្រូវការធនធានបន្ថែម<br>(៦) |
|---|---|---|---|---|---|
| **ស្ថាប័ន** (គណៈកម្មាការ, អង្គការ, សមាគម,ក្រុមមនុស្ស.. | | | | | |
| **សំភារៈ និង ថវិកា** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| **ចំណេះដឹង/ជំនាញផ្សេងៗ** | | | | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ៣:** ..................................................................

| ប្រភេទនៃធនធាន<br>(១) | តើធនធានអ្វីដែលមាន ស្រាប់ក្នុងសហគមន៍<br>(២) | គាំទ្រដោយ រដ្ឋាភិបាល<br>(៣) | គាំទ្រដោយ អង្គការ, និង ផ្នែកឯកជន<br>(៤) | គាំទ្រដោយ សហគមន៍<br>(៥) | ភាពខ្វះចន្លោះ និង តម្រូវការធនធានបន្ថែម<br>(៦) |
|---|---|---|---|---|---|
| **ស្ថាប័ន** (គណៈកម្មាការ, អង្គការ, សមាគម,ក្រុមមនុស្ស.. | | | | | |
| **សំភារៈ និង ថវិកា** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| **ចំណេះដឹង/ជំនាញផ្សេងៗ** | | | | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ៤:** ..................................................................

| ប្រភេទនៃធនធាន | តើធនធានអ្វីដែលមាន ស្រាប់ក្នុងសហគមន៍ | គាំទ្រដោយ រដ្ឋាភិបាល | គាំទ្រដោយ អង្គការ, និង ផ្នែកឯកជន | គាំទ្រដោយ សហគមន៍ | ភាពខ្វះចន្លោះ និង តម្រូវការធនធានបន្ថែម |
|---|---|---|---|---|---|

| (១) | (២) | (៣) | (៤) | (៥) | (៦) |
|---|---|---|---|---|---|
| **ស្ថាប័ន** (គណៈកម្មាការ, អង្គការ, សមាគម,ក្រុមមនុស្ស.. | | | | | |
| **សំភារៈ និង ថវិកា** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| **ចំណេះដឹង/ជំនាញផ្សេងៗ** | | | | | |

**មុខសញ្ញាគ្រោះថ្នាក់ ស្ថិតក្នុងអាទិភាពទី ៥:** .................................................................

| **ប្រភេទនៃធនធាន** (១) | តើធនធានអ្វីដែលមានស្រាប់ក្នុងសហគមន៍ (២) | គាំទ្រដោយរដ្ឋាភិបាល (៣) | គាំទ្រដោយ អង្គការ, និង ផ្នែកឯកជន (៤) | គាំទ្រដោយសហគមន៍ (៥) | ភាពខ្វះចន្លោះ និង តម្រូវការធនធានបន្ថែម (៦) |
|---|---|---|---|---|---|
| **ស្ថាប័ន** (គណៈកម្មាការ, អង្គការ, សមាគម,ក្រុមមនុស្ស.. | | | | | |
| **សំភារៈ និង ថវិកា** | | | | | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| **ចំណេះដឹង/ជំនាញផ្សេងៗ** | | | | | |

## ➢ *ការណែនាំពីរបៀបបំពេញពិតមានក្នុងតារាង ៣:*

- **កូឡោនលេខ ២:** អ្នកវិភាគ ត្រូវបំពេញនូវពិតមាននានាដែលទាក់ទងនឹងធនធានផ្នែក ស្ថាប័ន, សំភារៈ, ថវិកា, ហេដ្ឋារចនាសម្ព័ន្ធ និង ចំណេះដឹង/ជំនាញផ្សេងៗ ដែលមាននៅក្នុងសហគមន៍របស់អ្នក ទោះបីធនធានទាំងនោះ ជារបស់ស្ថាប័នណាមួយក៏ដោយ ឱ្យតែមានស្រាប់នៅក្នុងសហគមន៍របស់អ្នក គឺត្រូវបានណែនាំសំរាប់ការរាប់បញ្ចូលទាំងអស់។
- **កូឡោនលេខ ៣:** អ្នកវិភាគ ត្រូវដកស្រង់ចេញពីធនធានទាំងឡាយដែលអ្នកបានបំពេញនៅក្នុងកូឡោនលេខ ២ ដើម្បីរកឱ្យឃើញថា តើក្នុងចំនោមធនធានទាំងនោះ មានធនធានណាខ្លះដែលជួយគាំទ្រដោយរដ្ឋាភិបាល។
- **កូឡោនលេខ ៤:** អ្នកវិភាគ ត្រូវដកស្រង់ចេញពីធនធានទាំងឡាយដែលអ្នកបានបំពេញនៅក្នុងកូឡោនលេខ ២ ដើម្បីរកឱ្យឃើញថា តើក្នុងចំនោមធនធានទាំងនោះ មានធនធានណាខ្លះដែលជួយគាំទ្រដោយអង្គការ និង ផ្នែកឯកជន។
- **កូឡោនលេខ ៥:** អ្នកវិភាគ ត្រូវដកស្រង់ចេញពីធនធានទាំងឡាយដែលអ្នកបានបំពេញនៅក្នុងកូឡោនលេខ ២ ដើម្បីរកឱ្យឃើញថា តើក្នុងចំនោមធនធានទាំងនោះ មានធនធានណាខ្លះដែលជួយគាំទ្រនិងផ្តួចផ្តើមឡើងដោយ សហគមន៍ខ្លួនឯង។

- **កូឡោនលេខ ៦ :** អ្នកវិភាគ ត្រូវគិតថាក្រៅពីធនធាននានាដូចបានបំពេញនៅក្នុងកូឡោនចាប់ពីលេខ ២ ដល់ លេខ ៥ រួចហើយ តើនៅមានធានធានណាខ្លះទៀតដែលសហគមន៍គិតថានៅពុំទាន់មានគ្រប់គ្រាន់ ឬពុំទាន់មាននៅឡើយ ដើម្បីបំពេញបន្ថែម។

  ***បញ្ជាក់:*** *អ្នកវិភាគ ត្រូវបំពេញពិតមានចូលទៅក្នុងតារាងមុខសញ្ញាគ្រោះថ្នាក់ស្ថិតក្នុងអាទិភាពចំនួន ៤ ទៀតជាបន្តបន្ទាប់ ផ្អែកលើរបៀបបំពេញពិតមានដូចបានណែនាំជាគំរូស្រាប់ខាងលើ។*

### ឃ- សេចក្តីសង្ខេបពីគ្រោះភ័យនៃគ្រោះមហន្តរាយ

សេចក្តីសង្ខេបពីគ្រោះភ័យនៃគ្រោះមហន្តរាយ គឺជាអត្ថបទខ្លី ឬបទយកការណ៍មួយ ដែលបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងនៃបញ្ហា ឬតម្រូវការអ្វីមួយ ដែលបានកើតឡើងកន្លងមក ឬកំពុងកើតឡើង។ វាមានសារៈសំខាន់ណាស់ សំរាប់យកមកធ្វើការវិភាគក្នុងការរៀបចំជាផែនការសកម្មភាពសំរាប់ត្រៀមបង្ការនិងឆ្លើយតបបាន។

នៅក្នុងខ្លឹមសារនៃសេចក្តីសង្ខេបនេះ គេចាំបាច់ត្រូវការពិតមានលំអិតបំផុត រួមមាន: ឈ្មោះភូមិសាស្ត្រ, ទីកន្លែង, ពេលវេលា, រដូវកាល, ចំនួន, មូលហេតុ, ផលប៉ះពាល់, តម្រូវការ និង ផ្អែកលើ What, When, Where, Why, Who និង How?

ឧទាហរណ៍ ១: ភូមិចំនួន១៧ នៃ០៥ឃុំ រួមមាន: ឃុំគ្រួស ចំបក់ កំពង់ចំឡង បាសាក់ និង ស្វាយធំ របស់ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង តែងជួបប្រទះបញ្ហាគ្រោះទឹកជំនន់ ចន្លោះពីខែ ៨-១១ ដែលបង្កឱ្យមានផលប៉ះពាល់ដល់អាយុជីវិត មុខរបរ ផ្ទះសម្បែង និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ជារៀងរាល់ឆ្នាំ។

ឧទាហរណ៍ ២: ផ្ទះសម្បែងប្រជាពលរដ្ឋពី៣០-៥០ខ្នង ទទួលរងការប៉ះពាល់ដោយសារខ្យល់ព្យុះ។ ក្នុងចំណោមនោះមានពី២០-៣០ខ្នង ទទួលរងការខូចខាតធ្ងន់ធ្ងរ។ ខ្យល់ព្យុះតែងកើតពីរវាង ខែ៤-៥ និង ខែ១០-១១ ជារៀងរាល់ឆ្នាំ។ ឃុំចំនួន០៦ នៃឃុំទាំង១៦ របស់ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង តែងរងការប៉ះពាល់ រួមមាន: ឃុំតាសួស គ្រួស ពោធិរាជ កំពង់ចម្លង ចំបក់ និង គោកព្រីង។

## ៤. ផែនការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ៤.១ យុទ្ធសាស្ត្រ

ក- ចក្ខុវិស័យនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ខ- គោលដៅយុទ្ធសាស្ត្រ

### ៤.២ ផែនការ និង សកម្មភាពយុទ្ធសាស្ត្រ

#### ក- ដំណាក់កាលត្រៀមបង្ការសំរាប់ឆ្លើយតប (មុនពេលគ្រោះមហន្តរាយ)

នៅក្នុងដំណាក់កាលនេះ ទាំងអ្នកផ្តល់បច្ចេកទេស និងអ្នករៀបចំផែនការ គួរផ្តោតទៅលើពិតមានសំខាន់ៗមួយចំនួនសំរាប់លើកយកមកសរសេរក្នុងផែនការ ដូចខាងក្រោម:

- **ការបណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពនានា** (វគ្គបណ្តុះបណ្តាល, សិក្ខាសាលា, វគ្គរំលឹក, លំហាត់សមយុទ្ធ, ជាដើម ។)
- **ការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីផលប៉ះពាល់ ឬវិធានការផ្សេងៗ** ដល់សហគមន៍ដែលងាយរងគ្រោះ ដើម្បីពួកគេមានសមត្ថភាពគ្រប់គ្រាន់លើការងារត្រៀមបង្ការ និងឆ្លើយតបទៅនឹងមុខសញ្ញាគ្រោះថ្នាក់ឬគ្រោះមហន្តរាយនានា ។
- **ប្រពន្ធ័ផ្តល់ពិតមានជាមុនពីគ្រោះមហន្តរាយផ្សេងៗ**(ពិសេសគ្រោះទឹកជំនន់) និង ឧបករណ៍ដទៃទៀត ដែលសាម៉ីមន្ទីរ/អង្គភាព(មានលទ្ធភាព) ឬ កិច្ចសហការជាមួយអង្គការជាដៃគូគ្រោងរៀបចំតម្លើង ឬ ធ្វើការជួសជុល នៅតាមតំបន់គោលដៅនានា ។
- **ការស្តុក និងការគ្រប់គ្រងឃ្លាំងស្តុកសំភារៈ និងជំនួយសង្គ្រោះ** (ការសាងសង់ឃ្លាំង សំរាប់ ស្តុកទុកសំភារៈ និង ស្បៀងអាហារផ្សេងៗ)
- **យុទ្ធសាស្ត្រសង្គ្រោះ ជំលៀស និងស្រាវជ្រាវរុករកជនរងគ្រោះ** : ការត្រៀមកំលាំងអន្តរាគមន៏, ឡានទឹក, ស្បៀងអាហារ, ថ្នាំសង្កូវ, អាវពោង, មធ្យោបាយសង្គ្រោះ, មធ្យោបាយទំនាក់ទំនង, បាវខ្សាច់, សាងសង់ឬស្តារប្រឡាយ, ដាក់លូ, ទ្វារទឹក, ប្រពន្ធ័ស្រោចស្រព និង ពូជស្រូវ/ដំណាំផ្សេងៗ ជាដើម ។ល ។
- **ការរៀបចំ និងការគ្រប់គ្រងទីទួលសុវត្ថិភាព (សំរាប់គ្រោះទឹកជំនន់):** ការលើកទីទួលឱ្យខ្ពស់ផុតពីកំពស់ទឹកជំនន់, សាងសង់ជំរកចល័ត, កៅស៊ូតង់, បំពាក់បង្គន់អនាម័យ, អណ្តូងស្នប់, ធុងចំរោះ និង គួរបង្កើតឱ្យមានគណៈកម្មការជួយគ្រប់គ្រងនិងទទួលខុសត្រូវនៅលើទីទួល (រួមមាន: គណៈកម្មការសុខភាព គណៈកម្មការស្បៀងអារហារ គណៈកម្មការសន្តិសុខ និង គណៈកម្មការពតិមាន/ទំនាក់ទំនង/សាធារណៈ ជាដើម) ។

### ខ- ដំណាក់កាលឆ្លើយតប និង សង្គ្រោះបន្ទាន់ (កំឡុងពេលគ្រោះមហន្តរាយ)

នៅក្នុងដំណាក់កាលនេះ ទាំងអ្នកផ្តល់បច្ចេកទេស និងអ្នករៀបចំផែនការ គួរផ្តោតទៅលើពិតមានសំខាន់ៗមួយចំនួនសំរាប់លើកយកមកសរសេរក្នុងផែនការ ដូចខាងក្រោម:

- **ការត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន(ពិនិត្យមើលស្ថានភាព):** ការចាត់តាំងកំលាំងចុះពិនិត្យមើលស្ថានភាពជាក់ស្តែង ដើម្បីក្តាប់បានពីទំហំនៃវិសាលភាពរបស់មុខសញ្ញា និងឥទ្ធិពលរបស់វា ដែលអាចបង្កការប៉ះពាល់ ក៏ដូចជា អាចត្រៀមជាវិធានការដើម្បីទប់ទល់ ។
- **ការព្យាករណ៍ និងការផ្តល់ពិតមានជាមុនពីគ្រោះមហន្តរាយ និងការផ្សព្វផ្សាយពីពិតមានព្យាករណ៏ ឬប្រកាសអាសន្នដល់សហគមន៏:** តាមរយៈពិតមានដែលទទួលបានពីការព្យាករណ៍តាមសារពិតមាន, វិទ្យុ ទូរទស្សន៍ និង ឧបករណ៍ផ្តល់ពិតមានជាមុនផ្សេងៗ ដែលបានតម្លើងនៅក្នុងតំបន់គោលដៅ ។

- **យុទ្ធសាស្ត្រសង្គ្រោះ ជំលៀស និងស្រាវជ្រាវរុករកជនរងគ្រោះ** (ការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានមនុស្ស សំភារៈ ថវិកា និងជំនាញផ្សេងៗ ដែលបានត្រៀមបំរុងនៅក្នុងដំណាក់កាលមុនគ្រោះមហន្តរាយ ធ្វើយ៉ាងណាឱ្យការឆ្លើយតបមានប្រសិទ្ធភាពខ្ពស់)។
- **ការគ្រប់គ្រងប្រជាពលរដ្ឋដែលបានជំលៀសមកស្នាក់នៅលើទីទួលសុវត្ថិភាព** (សំរាប់គ្រោះទឹកជំនន់): សំដៅដល់កិច្ចសហការរួមគ្នាមួយ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋដែលមកស្នាក់នៅជាបណ្តោះអាសន្នលើទីទួលសុវត្ថិភាព ត្រូវបានយកចិត្តទុកអំពីសុខុមាលភាពរបស់ពួកគេ ដូចជាៈ ជំរកស្នាក់នៅ, អាហារបរិភោគ, ទឹកស្អាតប្រើប្រាស់, បង្គន់អនាម័យ, សន្តិសុខ-សណ្តាប់ធ្នាប់ និង សីលធម៌រស់នៅ ជាដើម។
- **កម្មវិធី ផ្នែកសេវាសុខភាព អនាម័យ និងទឹកស្អាត** (វាជាការទទួលខុសត្រូវ និងយកចិត្តទុកដាក់ពីខាងវិស័យសុខាភិបាលដល់អ្នកជំលៀសទាំងនោះនូវ សេវាថែទាំសុខភាព, ថ្នាំសង្កូវ និង ការអប់រំពីបញ្ហាអនាម័យផ្សេងៗ ដូចជា ការហូបស្អាត ផឹកស្អាត និង រស់នៅស្អាត ជាដើម)។
- **ការវាយតំលៃនិងការប៉ាន់ប្រមាណពីផលប៉ះពាល់ និងសេចក្តីត្រូវការរបស់ជនរងគ្រោះ** (វាជាការចុះធ្វើការវាយតំលៃចំពោះមុខ ដើម្បីរកឱ្យឃើញពីតម្រូវការជាក់ស្តែងរបស់អ្នកជំលៀសទាំងនោះ ដើម្បីបានផ្តល់ការផ្គត់ផ្គង់បន្ថែម និងទាន់ពេលវេលា)។
- **ប្រតិបត្តិការឆ្លើយតបជំនួយសង្គ្រោះមបន្ទាន់** (ចំណុចនេះ សំដៅលើជំនួយគ្រប់ប្រភេទ ដែលមន្ទីរ អង្គភាព-ការិយាល័យ និងអង្គការជាតិ-អន្តរជាតិ សប្បុរសជននានា ព្រមទាំងអាជ្ញាធរមូលដ្ឋាន ដែលនាំយកទៅចែកជូនដល់អ្នកជំលៀសទាំងឡាយនៅតាមទីទួលសុវត្ថិភាព)។

### គ- ដំណាក់កាលស្តារ និង ជួសជុលឡើងវិញ (ក្រោយពេលគ្រោះមហន្តរាយ)

នៅក្នុងដំណាក់កាលនេះ ទាំងអ្នកផ្តល់បច្ចេកទេស និងអ្នករៀបចំផែនការ គួរផ្តោតទៅលើពិតមានសំខាន់ៗមួយចំនួនសំរាប់លើកយកមកសរសេរក្នុងផែនការ ដូចខាងក្រោមៈ

- **ការវាយតំលៃ និងការប៉ាន់ប្រមាណការខូចខាត និងសេចក្តីត្រូវការ ដើម្បីធ្វើការស្តារ និងជួសជុលឡើងវិញ** (ក្រោមការដឹកនាំ របស់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ឬស្រុក មន្ទីរ-អង្គភាព និងការិយាល័យជាសមាជិកសំខាន់ៗ ត្រូវចូលរួមក្នុងដំណើរចុះធ្វើការវាយតំលៃនិងប៉ាន់ប្រមាណលើទំហំនៃការខូចខាតជាក់ស្តែងនៅនឹងកន្លែងដែលបង្កឡើងដោយគ្រោះមហន្តរាយ។ ការរៀបចំផែនការ និងយុទ្ធសាស្ត្រ សំរាប់ការស្តារ-ជួសជុលឡើងវិញ (ផ្អែកលើលទ្ធផលដែល បានចុះធ្វើការវាយតំលៃ និងប៉ាន់ប្រមាណលើការខូចខាត ខាងលើ មន្ទីរវិស័យ អង្គភាព និង ការិយាល័យជាអ្នកអនុវត្តផែនការ ត្រូវរៀបចំជាផែនការសកម្មភាពរបស់ខ្លួនដើម្បីចុះជួយ អន្តរាគមន៍ជាបន្ទាន់លើបណ្តាផ្នែកទាំងឡាយដែល

បានរកឃើញថា មានការខូចខាតធ្ងន់ធ្ងរ និងចាំបាច់ត្រូវស្តារនិងជួសជុលឡើងវិញ ហើយវាសមស្របនឹងលទ្ធភាពរបស់មន្ទីរ-អង្គភាព និងការិយាល័យ ផងដែរ ។

- **ការអនុវត្តន៍គំរោងផែនការ និងយុទ្ធសាស្ត្រស្តារ-ជួសជុលឡើងវិញក្រោយគ្រោះមហន្តរាយ**

## ផ្នែកទី ៣:

## ការអនុវត្តន៍ផែនការ និង ការតាមដានត្រួតពិនិត្យ

### ១. ភារកិច្ច និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត និង ក្រុង-ស្រុក-ខណ្ឌ:

- សំរបសំរួលនិងណែនាំបច្ចេកទេសដល់ មន្ទីរវិស័យ អង្គភាព និង ការិយាល័យជុំវិញរាជធានី-ខេត្ត និង ក្រុង-ស្រុក-ខណ្ឌរបស់ខ្លួន ដើម្បីរៀបចំ, កែសំរួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំ លើផែនការរបស់ពួកគេ ។
- កៀងគរដៃគូទាំងក្នុងនិងក្រៅ (ថវិកា, សំភារៈ, បច្ចេកទេស) ដើម្បីជួយគាំទ្រដល់ផែនការសកម្មភាពរបស់ មន្ទីរ-អង្គភាពនិងការិយាល័យ ឱ្យមានប្រសិទ្ធភាព ។
- ត្រួតពិនិត្យតាមដាន និងវាយតំលៃ លើប្រសិទ្ធភាពនៃការអនុវត្តន៍ផែនការសកម្មភាពរបស់មន្ទីរ-អង្គភាព និងការិយាល័យជុំវិញខេត្តនិងស្រុក និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំរាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ ដើម្បីបានជ្រាប ។

### ២. ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ទីរ អង្គភាព និងការិយាល័យ ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត និងក្រុង-ស្រុក-ខណ្ឌ:

- ក្រោមជំនួយបច្ចេកទេសពីលេខាធិការដ្ឋាន សាម៉ីមន្ទីរ-អង្គភាព និងការិយាល័យជុំវិញរាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ គឺជាអ្នករៀបចំ, កែសំរួល និងធ្វើបច្ចុប្បន្នភាពលើផែនការរបស់ខ្លួនជាប្រចាំ ដើម្បីឱ្យផែនការនោះមានលក្ខណៈសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍ងាយរងគ្រោះ ។
- ជាអ្នកអនុវត្តផែនការដោយខ្លួនឯងក្រោមការណែនាំនិងចង្អុលបង្ហាញពីលេខាធិការដ្ឋានរាជធានី-ខេត្ត និង ក្រុង-ស្រុក-ខណ្ឌ ។
- ធ្វើរបាយការណ៍ជូនពីលទ្ធផលសកម្មភាពសំរេចបានជាទៀងទាត់ ជូនទៅលេខាធិការដ្ឋានរបស់ខ្លួន ។

### ឧបសម្ព័ន្ធ:

- ផែនទីរដ្ឋបាល, ផែនទីសេដ្ឋកិច្ច, ផែនទីគ្រោះមហន្តរាយនានា ដូចជា: ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ សត្វល្អិតបំផ្លាញដំណាំ... ។

- អនុក្រឹត្យ, ដីការ និងសេចក្តីណែនាំផ្សេងៗ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ (ថ្នាក់រាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ និង ឃុំ/សង្កាត់ ជាដើម)។
- បញ្ជីរាយឈ្មោះអង្គការជាតិ-អន្តរជាតិនានា ដែលកំពុងបំពេញការងារនៅក្នុងរាជធានី-ខេត្ត និង ក្រុង-ស្រុក-ខណ្ឌ និង ឃុំគោលដៅ ជាដើម ។ល។
- ឯកសារផ្សេងៗទៀត......

**ឧបសម្ពន្ធ (ឃ)**

# ផែនការត្រៀមបង្ការគ្រោះមហន្តរាយៈ ទឹកជំនន់

**មន្ទីរ/អង្គភាព/ការិយាល័យ :**............................................ (អ្នកតំណាង/ជនបង្គោលៈ.......................................... ទូរស័ព្ទៈ .................................)

| លេខ | ផែនការសកម្មភាពលំអិត | កត្តាវាស់វែង | អ្នកអនុវត្ត និង អង្គភាពពាក់ព័ន្ធ | ធនធានតម្រូវការ និង ថវិកាប៉ាន់ស្មាន | អាទិភាព និង ពេលវេលាអនុវត្ត | | | |
|---|---|---|---|---|---|---|---|---|
| | | | | | ខ្ពស់ | មធ្យម | ទាប | រយៈពេល |
| | | | | | | | | |
| **៥. ការខារត្រៀមបង្ការគ្រោះទឹកជំនន់ (មុនទឹកជំនន់)** | | | | | | | | |
| ៥.១ ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល ដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ឃុំ និង ភូមិៈ | | | | | | | | |
| *៥.១.១* | | | | | | | | |
| *៥.១.២* | | | | | | | | |
| ៥.២ ការផ្សព្វផ្សាយ និង បង្កើនការយល់ដឹងពីផលប៉ះពាល់ និង វិធានការត្រៀមបង្ការ ឆ្លើយតប ទៅនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ជាពិសេសទឹកជំនន់ ដល់ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់ងាយរងគ្រោះតាមដងទន្លេ មេគង្គ និង ទន្លេនានាក្នុងស្រុក : | | | | | | | | |
| *៥.២.១* | | | | | | | | |
| *៥.២.២* | | | | | | | | |
| ៥.៣ ប្រពន្ធ័ផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ និង ឧបករណ៏វាស់ស្ទង់កំពស់ទឹកជំនន់ដែលបានរៀបចំនៅតាមភូមិ-ឃុំ ជាគោលដៅ : | | | | | | | | |
| *៥.៣.១* | | | | | | | | |
| *៥.៣.២* | | | | | | | | |
| ៥.៤ ការស្តុក និងការគ្រប់គ្រងឃ្លាំងស្តុកសំភារៈ និង ជំនួយសង្គ្រោះ: | | | | | | | | |
| *៥.៤.១* | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥.៥ យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរុករកជនរងគ្រោះ ត្រូវបានរៀបចំ និង កំណត់ : | | | | | | | | |
| *៥.៥.១* | | | | | | | | |
| *៥.៥.២* | | | | | | | | |
| ៥.៦ ការរៀបចំ និង គ្រប់គ្រងទីទួលសុវត្ថិភាព មុនពេលមានគ្រោះទឹកជំនន់ : | | | | | | | | |
| *៥.៦.១* | | | | | | | | |
| *៥.៦.២* | | | | | | | | |
| ៥.៧ ការរៀបចំ និង គ្រប់គ្រងប្រពន្ធ័ផ្តល់ពិតមាន : | | | | | | | | |
| ៥.៧.១ | | | | | | | | |
| ៥.៧.២ | | | | | | | | |
| **៦. ប្រតិបត្តិការឆ្លើយតប និង សង្គ្រោះបន្ទាន់ (ក្នុងពេលទឹកជំនន់)** | | | | | | | | |
| ៦.១ ត្រួតពិនិត្យមុខសញ្ញាបង្កគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលអាចកើតឡើង ( ត្រួតពិនិត្យមើលស្ថានភាព): | | | | | | | | |
| *៦.១.១* | | | | | | | | |
| *៦.១.២* | | | | | | | | |
| ៦.២ ការព្យាករណ៍ ការផ្តល់ពិតមានជាមុនពីគ្រោះមហន្តរាយទឹកជំនន់ និង ការផ្សព្វផ្សាយពិតមានព្យាករណ៍, ប្រកាសអាសន្នដល់សហគមន៍ : | | | | | | | | |
| *៦.២.១* | | | | | | | | |
| *៦.២.២* | | | | | | | | |
| ៦.៣ យុទ្ធសាស្ត្រ សង្គ្រោះ ជំលៀស និង ស្រាវជ្រាវរកជនរងគ្រោះនៅរដូវទឹកជំនន់ ( កក្កដា ដល់ វិច្ឆិកា) : | | | | | | | | |
| *៦.៣.១* | | | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦.៤ ការគ្រប់គ្រងប្រជាពលរដ្ឋដែលបានជម្លៀស មកស្នាក់នៅលើទីទួលសុវត្ថិភាពនៅរដូវទឹកជំនន់ : | | | | | | |
| ៦.៤.១ | | | | | | |
| ៦.៥ កម្មវិធី ផ្នែកសេវាសុខភាព អនាម័យ និង ទឹកស្អាត : | | | | | | |
| *៦.៥.១* | | | | | | |
| ៦.៦ ការវាយតំលៃ និង ការប៉ាន់ប្រមាណពីផលប៉ះពាល់ និង សេចក្តីត្រូវការរបស់ជនរងគ្រោះ | | | | | | |
| *៦.៦.១* | | | | | | |
| ៦.៧ ប្រតិបត្តិការឆ្លើយតបជំនួយសង្គ្រោះបន្ទាន់ : | | | | | | |
| *៦.៧.១* | | | | | | |
| **៧. ការស្តារ និង ជួសជុលឡើងវិញ (ក្រោយទឹកជំនន់)** | | | | | | |
| ៧.១ ការវាយតំលៃ និង ការប៉ាន់ប្រមាណការខូចខាត និងសេចក្តីត្រូវការ ដើម្បីធ្វើការស្តារ និង ជួសជុលឡើងវិញ : | | | | | | |
| *៧..១.១* | | | | | | |
| ៧.២ ការរៀបចំផែនការ និង យុទ្ធសាស្ត្រស្តារ, ជួសជុលឡើងវិញ ផ្អែកលើលទ្ធផលវាយតំលៃក្នុងចំណុច (៧.១): | | | | | | |
| *៧..២.១* | | | | | | |
| ៧.៣ ការអនុវត្តន៍គំរោងផែនការ និង យុទ្ធសាស្ត្រស្តារ-ជួសជុលឡើងវិញ ក្រោយទឹកជំនន់ : | | | | | | |
| *៧.៣.១* | | | | | | |

ថ្ងៃទី............ខែ...........ឆ្នាំ ២០១....

ប្រធាន:....................................

ហត្ថលេខា ត្រា និង ឈ្មោះ